# កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ២០១៧ និងការវាយតម្លៃសមិទ្ធផល ៥ឆ្នាំ នៃការអនុវត្ត PFMRP

# សមិទ្ធផល បញ្ហាប្រឈម និងទិសដៅបន្តនៃការអនុវត្ត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨

# មាតិកានុក្រម


១ សមិទ្ធផលសម្រេចបានក្នុងរយៈពេល ៥ ឆ្នាំ (២០១៣-២០១៧)

២ បញ្ហាប្រឈម

៣ ទិសដៅនៃកម្មវិធីកែទម្រង់រយៈពេល ៥ ឆ្នាំ (២០១៨-២០២២)

៤ សន្និដ្ឋាន

# ១. សមិទ្ធផលសម្រេចបានក្នុងរយៈពេល ៥ ឆ្នាំ (២០១៣-២០១៧)

## I

**ថវិកា** កាន់តែជឿទុកចិត្ត និងក្លាយជាចលករឱ្យ **សេដ្ឋកិច្ចប្រែមុខមាត់ថ្មី**

១. ចំណូលចរន្តថវិការដ្ឋ**កើនឡើងទ្វេដង** ពី ៩,១ (២០១៣ អនុ.) ទៅ ១៨,៤ ទ្រីលានរ (២០១៨ គ្រោង)

២. **ចំណាយ** អនុវត្ត**ខិតជិតគោលដៅ** +/-៥% នៃ ឥណទានច្បាប់

៣. មាន**អតិរេកចរន្ត** និង**បន្ទុយឱនភាព** **សរុប**ពី -៧,០១% (២០១៣ អនុ.) មក -៥,៨៥% នៃ ផ.ស.ស (២០១៨ គ្រោង)

៤. **គ្មានបំណុលកកស្ទះ;** **បៀវត្ស និងប្រាក់បំណាច់មន្ត្រី** ផ្ទេរចូលគណនី **សប្តាហ៍ទី៤** នៃខែ

៥. **បំណុលសាធារណៈ** គ្រប់គ្រងត្រឹមត្រូវ <៤០% នៃ ផ.ស.ស

## II

**បុរេលក្ខខណ្ឌ** សំខាន់ៗ ត្រូវបានកសាង និងពង្រឹងបន្ថែម ដើម្បីធានា **គណនេយ្យភាពហិរញ្ញវត្ថុ**

១. **ប្លង់គណនេយ្យថ្មី**

២. **ចំណាត់ថ្នាក់ទាំង៧** នៃ **មាតិកាថវិកា**

៣. **មុខងាររបេឡា** នៅរតនាគារ **លុបបំបាត់ទាំងស្រុង**

៤. **ប្រព័ន្ធ FMIS** ដាក់ឱ្យអនុវត្ត ដំ.ទី១ និងទី២

៥. មុខងារ **សវនកម្មផ្ទៃក្នុង** បង្កើតនៅគ្រប់ក្រសួង ស្ថាប័ន

៦. **តម្លាភាពថវិកា** ត្រូវបានបង្កើន

៧. **ច្បាប់ និងបទប្បញ្ញត្តិ** ពាក់ព័ន្ធការអនុវត្តថវិកា

# ១. សមិទ្ធផលសម្រេចបានក្នុងរយៈពេល ៥ ឆ្នាំ (២០១៣-២០១៧)

## III

**ក្របខ័ណ្ឌថវិកាកម្មវិធី** ត្រូវបានរៀបចំ ពង្រឹង និងពង្រីក ជាឧបករណ៍ផ្សារភ្ជាប់ថវិកានឹងគោលនយោបាយ

- ១. **ថវិកាកម្មវិធីពេញលេញ** នៅគ្រប់ក្រសួងស្ថាប័ន
- ២. គ្រប់ក្រសួងស្ថាប័ន មាន **រចនាសម្ព័ន្ធគោលនយោបាយ និង ផ.យ.ថ**
- ៣. ក្របខ័ណ្ឌ **គតិយុត្ត** នៃការរៀបចំ និងអនុវត្តថវិកាកម្មវិធី
- ៤. **យន្តការអង្គភាពថវិកា÷** ជំរុញតម្លាភាព គណនេយ្យភាព ការផ្ទេរសិទ្ធិអំណាច និងការទទួលខុសត្រូវ

## IV

**សមត្ថភាពមន្ត្រី** ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រឹង

- ១. **ការបណ្តុះបណ្តាល** រៀបចំជាបន្តបន្ទាប់ និងមាន**លក្ខណៈ**ប្រមូលផ្តុំ
- ២. **គុណភាព**នៃ **ផ.យ.ថ, សំណើគម្រោងថវិកា** ប្រចាំឆ្នាំ និង **ការចរចាថវិកា**
- ៣. កំណើន **ប្រសិទ្ធភាព**នៃការ**អនុវត្តថវិកា÷** ទំហំអនុវត្តធៀបឥណទាន

# ១. សមិទ្ធផលសម្រេចបានក្នុងរយៈពេល ៥ ឆ្នាំ (២០១៣-២០១៧)

V

១. សិក្ខាសាលាផ្សព្វផ្សាយ ជូនគ្រប់ក្រសួងស្ថាប័ន និងរដ្ឋ. រាជធានី ខេត្ត

២. សិក្ខាសាលាផ្សព្វផ្សាយ ជូនយុវជន និងសិស្សនិស្សិត នៅគ្រឹះ. ឧត្តមសិក្សា

**ការយល់ដឹង និងការចូលរួម** អនុវត្តកម្មវិធីកែ-ទម្រង់កើនឡើង

៣. ឧបករណ៍ផ្សព្វផ្សាយសំបូរបែប ព្រឹត្តបត្រ, ខិត្តបណ្ណ, គេហទំព័រ, បណ្ដាញសង្គម, សារព័ត៌មាន, កិច្ចសម្ភាសន៍, វីដេអូ

៤. កម្រងសម្រង់បទប្បញ្ញត្តិ គតិយុត្ត ពាក់ព័ន្ធ

VI

**ទិសដៅជាយុទ្ធសាស្ត្រ** ត្រូវបាន អនុម័ត ជាប្រទីប និង ជាផែនទីគោចរ ក្នុង ការបន្តដំណើរទៅមុខ

១. យុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥ អនុម័តដោយ គណៈរដ្ឋមន្ត្រី

# ២. បញ្ហាប្រឈម

## កត្តាស្ថាប័ន

១. **យន្តការសម្របសម្រួលរួម** រវាងអង្គភាពជំនាញពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមួយក្រសួង ស្ថាប័នជាពិសេស ក្នុងការអនុវត្តថវិកា **នៅពុំទាន់ប្រមូលផ្តុំ**

២. **ឆន្ទៈ ការយល់ដឹង និងការចូលរួម**របស់ក្រសួង ស្ថាប័ន កើនឡើងជាលំដាប់ ប៉ុន្តែ**នៅពុំទាន់គ្រប់គ្រាន់** ក្នុងការជំរុញការងារកែទម្រង់ឱ្យកាន់តែមានសន្ទុះជាពិសេស កម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់

៣. **ពុំទាន់មានផែនការសកម្មភាព**សម្រាប់ផ្សារភ្ជាប់**កំណែទម្រង់ទាំងបី**

## កត្តាបច្ចេកទេស និងធនធានមនុស្ស

១. **ការរៀបចំផែនការសកម្មភាពលម្អិត**របស់អង្គភាពក្រោមឱវាទក្រសួង-សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័ន **នៅពុំទាន់ឆ្លើយតបនឹងផែនការសកម្មភាពរួម**របស់កម្មវិធីកែទម្រង់

២. **ការបណ្តុះបណ្តាល**ត្រូវបានរៀបចំច្រើន ប៉ុន្តែភាគច្រើនជាការបញ្ជ្រាបការយល់ដឹង ដោយ**នៅពុំទាន់បានរៀបចំរយៈពេលមធ្យម និងវែង** ដែលសំដៅបង្កើនសមត្ថភាពជំនាញរបស់មន្ត្រីពាក់ព័ន្ធ

## កត្តាហិរញ្ញវត្ថុ

១. **ថវិការដ្ឋសម្រាប់គាំទ្រកម្មវិធីកែទម្រង់នៅមានកម្រិត** ដោយនៅមានសេចក្តីត្រូវការគាំទ្រពីហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍

២. ការរៀបចំ**ការឧបត្ថម្ភលើកទឹកចិត្តដល់ក្រុមការងារកែទម្រង់**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួង ស្ថាប័ន នៅកំពុងរៀបចំវិធាន និងនីតិវិធីនៅឡើយ ដើម្បីអាចអនុវត្តក្នុងឆ្នាំ២០១៨ នេះ។

# ៣. ទិសដៅនៃកម្មវិធីកែទម្រង់ រយៈពេល ៥ ឆ្នាំ (២០១៨-២០២២)

## ទិសដៅរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បូរណភាពនៃការគោរពវិន័យថវិកា
- ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍, ទាំងក្នុងផ្នែកប្រតិបត្តិការ
- ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ

# ៣.១. ទិសដៅបន្តសម្រាប់ កសហវ (១/២)

១ រៀបចំក្របខ័ណ្ឌគោលនយោបាយពន្ធរយៈពេលមធ្យម ២០១៩-២០២៣

២ អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥

៣ ពង្រឹង និង ពង្រីកការអនុវត្តប្រព័ន្ធ FMIS ស្របតាមផែនការយុទ្ធសាស្ត្រដំណាក់កាលទី២

៤ រៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យម (MTFF) និង ថវិការយៈពេលមធ្យម (MTBF)

៥ ធ្វើវិសោធនកម្មច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ដើម្បីឱ្យស្របតាមបរិបទប្រព័ន្ធថវិកាថ្មី

៦ បញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

# ៣.១ ទិសដៅបន្តសម្រាប់ គសហវ (២/២)

- ៧ រៀបចំយុទ្ធសាស្ត្រនៃកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៨-២០២៥
- ៨ រៀបចំយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥
- ៩ រៀបចំក្របខ័ណ្ឌវិនិយោគសាធារណៈ និង ភាពជាដៃគូរវាងរដ្ឋនិងឯកជន
- ១០ រៀបចំផែនទីចង្អុលបង្ហាញផ្លូវគណនេយ្យបង្គរ
- ១១ រៀបចំមគ្គុទេសក៍គ្រប់គ្រងហិរញ្ញត្ថុសាធារណៈរាជរដ្ឋាភិបាល
- ១២ រៀបចំមូលនិធិ PFMRP គ្រប់ជ្រុងជ្រោយ និងកសាងសមត្ថភាពធនធានមនុស្សលើវិស័យហិរញ្ញវត្ថុសាធារណៈ

# ៣.២. ទិសដៅបន្តសម្រាប់ក្រសួង ស្ថាប័ន (១/២)

១ ត្រួតពិនិត្យការអនុវត្តថវិកាកម្មវិធីទាំងពាក់កណ្ដាលឆ្នាំ និងប្រចាំឆ្នាំ (គោលបំណង ៣១)

២ ពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (គោលបំណង ៣២)

៣ រៀបចំរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ឱ្យស្របតាមថវិកាកម្មវិធី (គោលបំណង ៣៣)

៤ គ្រប់គ្រង និងអនុវត្តការប្រមូលចំណូល (គោលបំណង ១១)

៥ ពង្រឹងការរៀបចំកម្មវិធីចំណូល-ចំណាយ (គោលបំណង ១៤ និង១១)

# ៣.២. ទិសដៅបន្តសម្រាប់ក្រសួង ស្ថាប័ន (២/២)

៦ ពង្រឹងតម្លាភាពលទ្ធកម្មសាធារណៈ និងតម្លាភាពថវិកា (គោលបំណង ២៥)

៧ គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (គោលបំណង ២៥)

៨ ចូលរួមអនុវត្តប្រព័ន្ធ FMIS (១) រៀបចំ SOP, (២) ការគ្រប់គ្រងការផ្លាស់ប្តូរ និង (៣) អង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធ (គោលបំណង ២១)

៩ ពង្រឹងមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច (គោលបំណង ៣៥)

១០ ពង្រឹងសមត្ថភាព និងការផ្សព្វផ្សាយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ (គោលបំណង ៥១, ៥២ និង ៥៣)

# ៤. សន្និដ្ឋាន

សមិទ្ធផលសម្រេចបាននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា គឺបាននិងកំពុងកសាង និងពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអាចធ្វើការវាយតម្លៃជារួម ដូចតទៅ÷

- ✓ ថវិកាកាន់តែមានភាពជឿទុកចិត្ត និងបានក្លាយជាកម្លាំងចលករក្នុងការទ្រទ្រង់ និងជំរុញកំណើនសេដ្ឋកិច្ច;
- ✓ បុរេលក្ខណៈសំខាន់ៗត្រូវបានកសាង និងពង្រឹងបន្ថែម ដើម្បីធានាគណនេយ្យភាពហិរញ្ញវត្ថុ;
- ✓ ក្របខ័ណ្ឌថវិកាកម្មវិធី ត្រូវបានរៀបចំ ពង្រឹង និងពង្រីកការអនុវត្ត ដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល;
- ✓ សមត្ថភាពមន្ត្រីនៃក្រសួង ស្ថាប័នក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានពង្រឹង;
- ✓ ការយល់ដឹង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់កើនឡើងជាលំដាប់ ។

# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**“ប្រព័ន្ធ យន្តការ ក្របខ័ណ្ឌគតិយុត្ត និងធនធានមនុស្ស”**
គឺជាកត្តាគន្លឹះកំណត់ជោគជ័យ ធានាវិន័យ តម្លាភាព គណនេយ្យភាព
ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

## សូមអរគុណ!